ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការទទួលស្គាល់ វិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការ បង្កើតសាកលវិទ្យាល័យ
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និងកីឡា តាមលិខិតលេខ ១៣២០ អយក.ឧស ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៦

ស ម្រេ ច

មាត្រា ១ : ទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា **វិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍** " Institute of Management and Development " ហៅកាត់ជាភាសាខ្មែរ " **វ.គ.អ** ". និងហៅកាត់ជាភាសាអង់គ្លេស **I.M.D** ។

មាត្រា ២ : វិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍ មានទីតាំងស្ថិតនៅ ភូមិពាលញែក២ ឃុំផ្ទះព្រៃ ស្រុកសំពៅមាស នៅទីរួមខេត្តពោធិ៍សាត់ និងស្ថិតនៅក្រោមឱវាទ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៣ : វិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍ ធ្វើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្ររង សិក្សារយៈពេល ២ឆ្នាំ និងបរិញ្ញាបត្រ សិក្សារយៈពេល ៤ឆ្នាំ ជាមធ្យម ។ ក្នុងរយៈពេលបីខែ បន្ទាប់ពីថ្ងៃចាប់ដំណើរការ វិទ្យាស្ថាននេះ ត្រូវរៀបចំកម្មវិធីសិក្សាលំអិត តាមកម្រិត និងមុខជំនាញ ដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៤ : វិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍ មានមហាវិទ្យាល័យចំនួន ០៤ :

- មហាវិទ្យាល័យភាសាបរទេស
- មហាវិទ្យាល័យគ្រប់គ្រង
- មហាវិទ្យាល័យនីតិសាស្ត្រ និងសេដ្ឋកិច្ច
- មហាវិទ្យាល័យបច្ចេកវិទ្យាព័ត៌មាន

ទៅអនាគតវិទ្យាស្ថាននេះ អាចបើកសាខា មហាវិទ្យាល័យ មុខជំនាញ ឬប្រភេទបណ្តុះបណ្តាលដទៃទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៥ : វិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍ មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេច លើគោលនយោបាយ ផែនការអភិវឌ្ឍ កម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត ។

មាត្រា ៦ : តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែង នៃវិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថាន និងមានការឯកភាព ពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៧ : វិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍ ត្រូវគោរព និងអនុវត្តតាមការណែនាំ និងបទដ្ឋានដែលពាក់ព័ន្ធនឹងការងារបណ្តុះបណ្តាល របស់ក្រសួងអប់រំ យុវជន និងកីឡា និងច្បាប់របស់រាជរដ្ឋាភិបាល សំដៅធានាគុណភាពអប់រំ ។

មាត្រា ៨ : នាយកនៃវិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍ មានភារកិច្ចទទួលខុសត្រូវ នៅចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងវិទ្យាស្ថាន ធានាឱ្យបាននូវសុវត្ថិភាព សណ្តាប់ធ្នាប់សង្គម និងធ្វើរបាយការណ៍រាល់សកម្មភាពសិក្សាជូននាយកដ្ឋានឧត្តមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់ ។

មាត្រា ៩ : និស្សិត ដែលបានរៀនចប់កម្មវិធីសិក្សា របស់វិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍ និងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងឯកទេស ដែលបានសិក្សា។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយវិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍ ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី វិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍ បំពេញ និងអនុវត្តបានតាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ១០ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្ថាប័នពាក់ព័ន្ធ និងវិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែឧសភា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលាខេត្តពោធិ៍សាត់
- ដូចមាត្រា ១០
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ